**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ
ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**
ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម៖ **បារាំង**
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jul-2013, 14:33
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**
ប្រភេទនៃចំណាត់ថ្នាក់៖
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖
ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖
ហត្ថលេខា៖

---

**សំណើសុំផ្តល់ព័ត៌មាន ដែលបានដាក់ដោយមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការកោះហៅសាក្សី នូ ម៉ៅ ឱ្យចូលខ្លួនមកចំពោះមុខសវនាការ**

---

ដាក់ដោយ៖

**មេធាវីការពារក្តីលោក ខៀវ សំផន**
មេធាវី គង់ សំអុន
មេធាវី Anta GUISSÉ
មេធាវី Arthur VERCKEN
មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យូរ ឧត្តរា
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Mathilde CHIFFERT

កញ្ញា Soumeya MEDJEBEUR

កញ្ញា Vera MANUELLO

កញ្ញា អ៊ួច ស្រីផាត

លោកស្រី សុគន្ធ ម៉ូនីកា

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានដាក់សំណើសុំមួយដោយផ្អែកលើមូលដ្ឋាននៃវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដែលស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យមានការផ្តល់នូវព័ត៌មានបន្ថែម ដើម្បីស្វែងរកទីលំនៅរបស់សាក្សីសំខាន់ នូ ម៉ៅ[1] ដើម្បីអញ្ជើញគាត់ឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក. ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[2]។ នៅឆ្នាំ ១៩៨១ សាក្សីរូបនេះត្រូវបានសម្ភាសដោយលោក Benedict KIERNAN នៅឧត្តុង្គ។ កំណត់ត្រាសរសេរដោយដៃនៃកិច្ចសម្ភាសមាននៅក្នុងសំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេតរួចហើយ[3]។

២. នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ បើទោះបីជាមានការជំទាស់ពីសំណាក់មេធាវីការពារក្តីពីរក្រុមក៏ដោយ[4] ក៏អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់ថា សាក្សីត្រូវបានគេស្វែងរកឃើញ ហើយគាត់បានត្រៀមខ្លួនរួចជាស្រេចក្នុងការចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក.[5]។

៣. នៅថ្ងៃទី ១៩ និង ២០ ខែ មិថុនា ឆ្នាំ ២០១៣ សាក្សី នូ ម៉ៅ បានចូលខ្លួនមកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំបើកកិច្ចស៊ើបសួរស្របតាមវិធាន ៩៣ អំពីទីកន្លែងស្នាក់នៅរបស់សាក្សីសក្តានុពល នូ មុក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E266**។

[2] ដូចយោងខាងលើ កថាខណ្ឌ ១។

[3] កំណត់ហេតុរបស់ Ben KIERNAN ឯកសារ **D313/1.2.405**។

[4] *ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំបើកកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៩៣ អំពីទីកន្លែងស្នាក់នៅរបស់សាក្សីសក្តានុពល នូ មុក* ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **E266/1**, ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ផ្អែកលើមូលដ្ឋាននៃវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដែលស្នើសុំឱ្យអង្គជំនុំជម្រះចាត់ឱ្យមានការផ្តល់ព័ត៌មានបន្ថែមដើម្បីតាមរកទីកន្លែងរបស់សាក្សីសក្តានុពល នូ មុក ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **E266/2**។

[5] អនុស្សរណៈចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E266/3**។

៤. នាថ្ងៃដំបូងនៃការផ្តល់សក្ខីកម្ម នៅពេលដែលត្រូវបានចោទសួរដោយសហព្រះរាជអាជ្ញា សាក្សី នូ ម៉ៅ បានបង្ហាញដល់អង្គជំនុំជម្រះនូវរូបថតរបស់មនុស្សម្នាក់ដែលគាត់បានប្រាប់ថា ជារូបថតរបស់លោក Ben KIERNAN។ ដោយមានការស្នើសុំពីសហព្រះរាជអាជ្ញាអន្តរជាតិ និងដោយពុំបានទុកឱកាសឲ្យភាគីដើម្បីពិនិត្យលើរូបថតនេះឲ្យបានច្បាស់លាស់ អង្គជំនុំជម្រះបានបញ្ជាឲ្យដាក់បញ្ចូលរូបថតនោះទៅក្នុងសំណុំរឿង ដោយមានលេខសម្គាល់ E3[6]។

៥. កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានចោទសួរទៅលើសាក្សីរូបនេះ និងបានសាកសួរសាក្សីរូបនេះពាក់ព័ន្ធនឹងប្រភពនៃរូបថតដែលសាក្សីបានបង្ហាញដល់អង្គជំនុំជម្រះកាលពីមួយថ្ងៃមុន។ អង្គជំនុំជម្រះបានផ្អាកការតាំងសំណួររបស់សហមេធាវីអន្តរជាតិ[7] ដើម្បីបញ្ជាក់ដល់ភាគីថា ឯកសារត្រូវបានផ្តល់ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") "*ដើម្បីធានាឲ្យបានច្បាស់ថា បុគ្គលដែលត្រូវបានគេទាក់ទង ពិតជាអ្នកដែលអង្គជំនុំជម្រះស្វែងរកប្រាកដមែន។ ដូច្នេះ សាក្សីរូបនោះពុំត្រូវបានសួរសំណួរផ្សេងទៀតឡើយ*"[8]។

៦. នៅពេលនោះ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានធ្វើការតវ៉ាសាជាថ្មីប្រឆាំងទៅនឹងការណ៍ដែលអង្គជំនុំជម្រះប្រើសិទ្ធិផ្អាកការតាំងសំណួររបស់មេធាវីម្នាក់[9] ដែលមានបំណងចោទសួរទៅលើសាក្សីពាក់ព័ន្ធនឹងប្រភពនៃឯកសារដែលគេសង្ស័យ។ ជាក់ស្តែង វាជារឿងមួយដែលសំខាន់ និងស្របច្បាប់ ក្នុងការដែលភាគីត្រូវបានគេជូនដំណឹង និងអនុញ្ញាតឲ្យធ្វើការដេញដោលដោយពុំចាំបាច់ឲ្យចៅក្រមធ្វើការឆ្លើយតបជំនួសឲ្យសាក្សីដែលត្រូវបានចោទសួរឡើយ។

៧. នៅក្នុងអំឡុងនៃការតាំងសំណួររបស់ក្រុមមេធាវីការពារក្តី លោក នូ ម៉ៅ បានលើកឡើងថា ថ្មីៗនេះ លោកក៏បានអាន "កំណត់ហេតុរបស់លោក *Ben KIERNAN*" ជាភាសាខ្មែរដែរ៖

---

[6] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1** ទំព័រ ៧៧ (ភាសាបារាំង)។

[7] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៥ និង ៣៦ (ភាសាបារាំង)។

[8] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៤ (ភាសាបារាំង)។

[9] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៥ និង ៣៦ (ភាសាបារាំង)។

*"សំណួរ៖ ហើយកំណត់ហេតុជាភាសាខ្មែរដែលលោកមាននោះ តើលោកមាននៅចាំដែរឬទេ នរណាជាអ្នកផ្តល់កំណត់ហេតុនោះដល់លោក? (...)*

*ចម្លើយ៖ ខ្ញុំពុំបានចងចាំឈ្មោះអ្នកដែលបានផ្តល់ឯកសារនោះដល់ខ្ញុំទេ។*

*សំណួរ៖ តើលោកអាចគ្រាន់បញ្ជាក់បានដែរឬទេថា ឯកសារនេះត្រូវបានផ្តល់ឱ្យកាលពីសប្តាហ៍មុន ពីខែមុន? តើនៅក្នុងឆ្នាំនេះ ឬឆ្នាំមុន?*

*ចម្លើយ៖ គឺនៅពេលដែលរូបខ្ញុំត្រូវបានគេកោះហៅឱ្យចូលមកផ្តល់សក្ខីកម្ម"*[10] ។

*សក្ខីកម្មរបស់សាក្សីអស់ទាំងនេះ ហាក់ដូចជាបង្ហាញឱ្យឃើញថា កំណត់ហេតុក៏ត្រូវបានផ្តល់ដល់សាក្សីពីសំណាក់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដើម្បីឱ្យសាក្សីអាន។ សាក្សីក៏បានបញ្ជាក់ផងដែរថា ខ្លួនបានអានកំណត់ហេតុនោះ " ជាច្រើនលើកច្រើនសា"* [11] ។

៨. តាមរយៈសំណើសុំនេះ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះ ឱ្យបង្គាប់ដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ធ្វើការពន្យល់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌជាក់លាក់នៃការកំណត់អត្តសញ្ញាណលោក Ben KIERNAN ពីសំណាក់សាក្សីរូបនេះ មិនថាការកំណត់នោះត្រូវបានធ្វើមុនពេលដែលមានការផ្តល់នូវរូបថតដែលមានសរសេរបញ្ជាក់ប៉ុណ្ណោះទេ ប៉ុន្តែ រួមទាំងខណៈពេលមួយច្បាស់លាស់ដែលរូបថតនេះត្រូវបានបង្ហាញដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញផងដែរ។ ការស៊ើបអង្កេតក៏ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ផងដែរទៅលើបញ្ហាដែលថា តើនរណាជាអ្នកសម្រេចប្រគល់រូបថតនោះទៅក្នុងដៃរបស់សាក្សី ហើយហេតុដូចម្តេចបានជាមានការសម្រេចដូច្នេះ។

៩. មេធាវីការពារក្តីក៏ស្នើសុំផងដែរថា ការស៊ើបអង្កេតនេះត្រូវកំណត់ថាតើនរណាជាអ្នកណែនាំអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឱ្យសាក្សីធ្វើការអាន ព្រមទាំងប្រគល់ដល់សាក្សីនូវឯកសារ

[10] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៩ និង ៤០ (ភាសាបារាំង)។

[11] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៩ (ភាសាបារាំង)។

កំណត់ហេតុរបស់លោក Ben KIERNAN ជាភាសាខ្មែរ ដែលកំណត់ហេតុទាំងនោះមិនស្ថិតនៅក្នុងប្រភេទនៃសក្ខីកម្មពីមុនឡើយ បើផ្អែកតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ E141[12]។

១០. ដោយសង្កេតឃើញអំពីសក្ខីកម្មដែលមានលក្ខណៈប្រែប្រួលរបស់លោក នូ ម៉ៅ នៅចំពោះមុខអង្គជំនុំជម្រះ ការស៊ើបអង្កេតនេះមានលក្ខណៈសំខាន់ក្នុងក្របខណ្ឌនៃការពិនិត្យអំពីតម្លៃជាភ័ស្តុតាងដល់សក្ខីកម្មដែលផ្តល់ដោយសាក្សីរូបនេះ។

## I. <u>អំពីច្បាប់ដែលត្រូវអនុវត្ត និងការអនុវត្តដែលបានកំណត់ដោយអង្គជំនុំជម្រះ</u>

### ១. <u>ការកោះហៅសាក្សីពីសំណាក់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ</u>

១១. វិធានផ្ទៃក្នុងបានចែងអំពីលក្ខខណ្ឌនៃការកោះហៅសាក្សី។ វិធាននេះបានចែងលម្អិតអំពីដំណាក់កាលនានានៃការស្វែងរកសាក្សី និងកោះហៅសាក្សី។ វិធាន ៤១ ដែលមានចំណងជើងថា "ដីកាកោះ" បានចែងថា៖

"*៣. ដីកាកោះទាំងអស់ត្រូវបញ្ជូនតាមអាសយដ្ឋានចុងក្រោយបង្អស់ដោយក្រឡាបញ្ជី នគរបាលយុត្តិធម៌ ឬមន្ត្រីដែលត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះវិសាមញ្ញ តាមមធ្យោបាយណាមួយសមស្រប។ (...) ការបញ្ជូនដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវសរសេរចូលក្នុងរបាយការណ៍ដោយបញ្ជាក់អំពីមធ្យោបាយបង្គាប់ឱ្យចូលខ្លួន កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែង រួមទាំងកាលៈទេសៈ ពាក់ព័ន្ធដទៃទៀត ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីដែលបំពេញកិច្ចការនោះ និងដាក់ចូលក្នុងសំណុំរឿង។*

*៤. បុគ្គលដែលទទួលភារៈជាអ្នកប្រគល់ដីកាទៅឱ្យជនណាម្នាក់ ត្រូវអនុវត្តទៅតាមភារកិច្ចរបស់ខ្លួន និងខិតខំឱ្យអស់ពីលទ្ធភាពដើម្បីប្រគល់ដីកា និង ទទួលបានមកវិញនូវសេចក្តីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកា ។ សេចក្តីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកានេះ ត្រូវដាក់ភ្ជាប់ទៅ*

[12] ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E141** ទំព័រ ៧-៨។

*និងរបាយការណ៍នៃការបំពេញកិច្ចការ។*"[13]

១២. អង្គភាពរបស់ អ.វ.ត.ក. ដែលមានភារកិច្ចស្វែងរកទីកន្លែង កំណត់អត្តសញ្ញាណ និងរ៉ាប់រងលើសាក្សីទាំងឡាយដែលត្រូវបានកោះហៅឲ្យចូលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ ដូច្នេះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញត្រូវទទួលខុសត្រូវលើការគោរពដល់នីតិវិធីនៃការកោះហៅសាក្សី ដូចមានចែងក្នុងវិធាន ៤១ នៃវិធានផ្ទៃក្នុង។ ក្នុងចំណោមកាតព្វកិច្ចទាំងឡាយរបស់ខ្លួន អង្គភាពគាំពារសាក្សី និងអ្នកជំនាញមានកាតព្វកិច្ចត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង នូវរបាយការណ៍នៃដីកាបង្គាប់ឲ្យចូលខ្លួន ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីដែលបំពេញកិច្ចការនោះផងដែរ។ ឯកសារដែលបានដាក់ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីកំណត់អត្តសញ្ញាណសាក្សី និង "រំលឹកការចងចាំឡើងវិញ" របស់សាក្សីដែលជាធាតុផ្សំមួយនៅក្នុងចំណោម "*ធាតុផ្សំសមស្រប*"ទាំងឡាយ នៃវិធាន ៤១ ដែលត្រូវតែបានលើកឡើងក្នុងរបាយការណ៍នៃដីកាបង្គាប់ឲ្យចូលខ្លួន។

## ២. __ការបង្ហាញសក្ខីកម្មពីពេលមុនដែលមានលក្ខណៈសមស្រប__

១៣. នៅក្នុងអនុស្សារណៈលេខ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចដូចខាងក្រោម៖

"*អង្គជំនុំជម្រះយល់ស្របថា ប្រសិទ្ធភាពនៃដំណើរការនីតិវិធីអាចបង្កើនបាន ប្រសិនបើមុនពេលផ្ដល់សក្ខីកម្ម សាក្សីត្រូវបានផ្ដល់ឱកាសឲ្យរំលឹកពីការចងចាំរបស់ពួកគេ ដោយពិនិត្យមើលចម្លើយមុនៗ របស់ពួកគេ។ អង្គជំនុំជម្រះនឹងធានាថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ទទួលបាននូវចម្លើយមុនៗរបស់សាក្សីម្នាក់ៗ ដើម្បីឲ្យសាក្សីអាចពិនិត្យមើលចម្លើយរបស់ពួកគេមុនពេលផ្ដល់សក្ខីកម្ម*"[14]។

[13] វិធាន ៤១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

[14] ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E141** ទំព័រ ៧-៨។

១៤. បន្ទាប់មក អង្គជំនុំជម្រះបានបញ្ជាក់អំពីជំហររបស់ខ្លួនជាច្រើនលើកច្រើនសា ហើយថ្មីៗនេះផងដែរ៖

“*វាគឺជាទម្លាប់ដែលអនុវត្តដ៏ខ្ជាប់ខ្ជួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលថាសាក្សីត្រូវបានផ្តល់ឱកាសដើម្បីរំលឹកការចងចាំរបស់ពួកគាត់ តាមរយៈការពិនិត្យឡើងវិញទៅលើកំណត់ហេតុស្តាប់ចម្លើយមុនៗរបស់ពួកគាត់ ដែលបានធ្វើជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតនៅមុនពេលការផ្តល់សក្ខីកម្មរបស់ពួកគាត់*”[15]។

១៥. បើយោងតាមសេចក្តីសម្រេចនេះ អង្គជំនុំជម្រះនឹងផ្តល់ដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញនូវសក្ខីកម្មដែលបានផ្តល់ដោយសាក្សីនៅក្នុងដំណាក់កាលនៃការស៊ើបសួរ។ មុនពេលដែលសាក្សីចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញនឹងផ្តល់ដល់ពួកគាត់នូវឯកសារកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគាត់ ដើម្បីឱ្យពួកគាត់អាន និង “រំលឹកការចងចាំ”។

១៦. នៅក្នុងអនុស្សារណៈរបស់ខ្លួនចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដែលអង្គជំនុំជម្រះផ្ញើជូនអង្គភាពគាំពារសាក្សី និងអ្នកជំនាញ អង្គជំនុំជម្រះបានកំណត់អំពីលក្ខខណ្ឌពាក់ព័ន្ធនឹងការបង្ហាញឯកសារដល់សាក្សី។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា ការប្រគល់ចម្លើយមុនៗរបស់សាក្សីឱ្យសាក្សីពិនិត្យឡើងវិញនេះ ជាការផ្តល់ឱកាសដល់សាក្សីក្នុងការបន្សាំទៅនឹងចម្លើយដែលគាត់ធ្លាប់បានផ្តល់កាលពីពេលមុន ឬបញ្ជាក់ថា ចម្លើយនោះពិតជាបានផ្តល់ដោយរូបគាត់ផ្ទាល់ “*ឧទាហរណ៍តាមរយៈការផ្ទៀងផ្ទាត់លើហត្ថលេខា និងស្នាមមេដៃ*”[16]។

១៧. ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមរំលឹកថា ការគោរពដល់វិធាននៃការបង្ហាញឯកសារដល់សាក្សីដែលត្រូវបានកោះហៅឱ្យចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺជារឿងដែលសំខាន់។ ការបង្ហាញឯកសារអាចធ្វើទៅបានតែចំពោះកំណត់ហេតុស្តាប់យកចម្លើយរបស់

---

[15] សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកុំផ្តល់កំណត់ហេតុនៃការស្តាប់ចម្លើយលើកមុនទាក់ទងនឹងទួលពោធិ៍ជ្រៃ ដល់សាក្សីនៅមុនការផ្តល់សក្ខីកម្ម ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E292/2/1** ទំព័រ ១។

[16] *ការប្រគល់ចម្លើយមុនៗឱ្យសាក្សីមុនពេលសាក្សីធ្វើសក្ខីកម្មនៅសវនាការ* ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E141/1** ទំព័រ ១។

សាក្សីដែលបានធ្វើក្នុងដំណាក់កាលស៊ើបសួរប៉ុណ្ណោះ ហើយយថាភូតភាពនៃកំណត់ហេតុទាំងនោះ អាចត្រូវបានទទួលស្គាល់តាមរយៈហត្ថលេខា ឬស្នាមមេដៃរបស់សាក្សី។

១៨. កំណត់ហេតុស្តាប់យកចម្លើយសាក្សីទាំងឡាយ ដែលពុំបានធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេតនៃ អ.វ.ត.ក. កំណត់ហេតុស្តាប់យកចម្លើយសាក្សីទាំងឡាយដែលពុំត្រូវបានគេពិនិត្យលើយថភូតភាព ដោយហេតុ ដែលគេពុំស្គាល់អំពីដើមទងនៃកំណត់ហេតុ អំពីលក្ខខណ្ឌនៃការរក្សាទុកកំណត់ហេតុ អំពីប្រភពដើមច្បាស់លាស់ កំណត់ហេតុស្តាប់យកចម្លើយសាក្សីទាំងឡាយ ដែលពុំត្រូវបានអានឡើងវិញ និងចុះហត្ថលេខាដោយសាក្សី ហើយខ្លឹមសារមានលក្ខណៈខ្វះចន្លោះ ឯកសារស្តាប់យកចម្លើយអស់ទាំងនេះមិនអាចត្រូវបានបង្ហាញដល់សាក្សីមុនពេលដែលសាក្សីចូលខ្លួនមកនៅចំពោះមុខអង្គជំនុំជម្រះឡើយ។

១៩. ជាក់ស្តែង ក្រោមហេតុផលដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងមួយគឺការធានាឲ្យបាននូវ "ប្រសិទ្ធិភាព"[17] ការបង្ហាញនូវឯកសារអស់ទាំងនេះ អាចបង្កើតឲ្យមានជាការច្របាច់បញ្ចូលទៅក្នុងសក្ខីកម្មរបស់សាក្សីនូវធាតុផ្សំដែលពុំត្រូវបានចាត់ទុកជាមុនថាមានសុពលភាព រួមទាំងព័ត៌មានទាំងឡាយដែលសាក្សីពុំដែលបានដឹង ហើយដែលព័ត៌មានទាំងនោះត្រូវបានបង្ហាញដល់សាក្សីដើម្បីជាការចងចាំផ្ទាល់ខ្លួនទៅវិញ។ ការអនុវត្តដូច្នេះ គឺផ្ទុយគ្នាទៅនឹងវត្ថុបំណងនៃការបង្ហាញការពិតដែលអង្គជំនុំជម្រះតែងតែរំលឹកជារឿយៗនោះ។

## ៣. ការមិនគោរពដល់បទបញ្ញត្តិដែលបានអនុម័តដោយអង្គជំនុំជម្រះ

២០. ជាចុងក្រោយ មេធាវីការពារក្តីលោក ខៀវ សំផន សូមធ្វើការរំលឹកថា ក្នុងករណីដែលមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមរយៈការប៉ុនប៉ងប្រើឥទ្ធិពលលើសាក្សី វិធាន ៣៥ នៃវិធានផ្ទៃក្នុងបានចែងថា៖

---

[17] ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E141** ទំព័រ ៧។

*"១. អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច នូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម:*

*ក-ផ្សាយចេញព័ត៌មានសម្ងាត់ ដោយរំលោភទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។*

*(...)*

*ឃ-គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬ ផ្តល់សំណូក ឬ ក៏ជ្រៀតជ្រែកលើសាក្សីណាម្នាក់ ឬលើអ្នកដែលអាចក្លាយជាសាក្សីដែលកំពុងផ្តល់ បានផ្តល់ ឬអាចផ្តល់ភស្តុតាងដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។*

*(...)*

*២. នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះមានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តិអំពើណាមួយដូចចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច ៖*

*(...)*

*ខ-ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឱ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ។"*

២១. បទបញ្ញត្តិនេះត្រូវបានអនុវត្ត ក្នុងករណីដែលមានការប្រព្រឹត្តផ្ទុយទៅនឹងវិធានដែលពាក់ព័ន្ធនឹងការប្រព្រឹត្តទៅអ.វ.ត.ក. និងសេចក្តីសម្រេចនានាដែលចេញដោយអង្គជំនុំជម្រះទៅលើបញ្ហានេះ។ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានចាត់ទុកថា ការជូនដំណឹងអំពីឯកសារទាំងឡាយដែលពុំមែនបានមកពីការស្តាប់ចម្លើយធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬដោយអ្នកស៊ើបអង្កេតនៃ អ.វ.ត.ក. គឺជាទង្វើនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។

## II. <u>អំពីការអនុវត្តជាក់ស្តែងរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញនៅក្នុងការស្វែងរកទីកន្លែង និងការកំណត់អត្តសញ្ញាណសាក្សី</u>

២២. នៅក្នុងសវនាការថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ក្រោមការប្រកាសរបស់លោកចៅក្រម LAVERGNE អង្គជំនុំជម្រះបានលើកឡើងថា រូបថតរបស់លោក KIERNAN ត្រូវបានផ្តល់ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីជាការកំណត់អត្តសញ្ញាណសាក្សី[18]។ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន យល់ឃើញថា ការផ្តល់នូវរូបថតនេះវាពុំមែនជារឿងមួយចាំបាច់នោះទេ។

២៣. ជាក់ស្តែង សំណួរដ៏សាមញ្ញ មានលក្ខណៈគ្រប់គ្រាន់អាចបង្ហាញថា សាក្សីគឺជាបុគ្គលដែលលោក KIERNAN បានសម្ភាសនិងកត់ត្រាចូលទៅក្នុងកំណត់ហេតុសរសេរដៃរបស់គាត់នោះ។ ជាក់ស្តែង ព័ត៌មានដែលអង្គភាពគាំពារសាក្សី និងអ្នកជំនាញមាន អាចឱ្យគេប្រើជាមូលដ្ឋានក្នុងការចោទសួរទៅលើសាក្សី នូ ម៉ៅ អំពីឈ្មោះបុគ្គលដែលគាត់ធ្លាប់បានជួប ថាតើគាត់ស្គាល់ឈ្មោះនោះដែរឬទេ និងអំពីមូលហេតុ ព្រមទាំងកាលទេសៈនានានៃកិច្ចសម្ភាសដែលគាត់បានធ្វើជាមួយបុគ្គលនោះ។ វាជារឿងមួយដែលគ្មានប្រយោជន៍ ក្នុងការបង្ហាញរូបថតទៅដល់សាក្សីរូបនោះ។

២៤. ទោះបីជាអង្គភាពគាំពារសាក្សី និងអ្នកជំនាញយល់ឃើញថា វាជារឿងមួយចាំបាច់ ក្នុងការបង្ហាញរូបថតនោះដល់សាក្សីក៏ដោយ ប៉ុន្តែតាមការពិត ការបង្ហាញឯកសារនេះដល់សាក្សីគឺជារឿងមួយដែលមិនចាំបាច់។

២៥. នៅចន្លោះពេលនេះ ក្រុមមេធាវីការពារក្តីយល់ឃើញថា ការកំណត់អត្តសញ្ញាណសាក្សីដោយផ្អែកលើរូបថត នឹងអាចយកជាការបាន លុះត្រាតែការកំណត់អត្តសញ្ញាណនោះត្រូវបានធ្វើនៅចំពោះមុខអង្គជំនុំជម្រះ ហើយដរាបណារូបថតដែលបង្ហាញដល់លោក នូ ម៉ៅ នោះ ពុំបានបញ្ជាក់ឈ្មោះលោក Ben KIERNAN សរសេរជាភាសាខ្មែរ។ ដោយគោរពតាមលក្ខខណ្ឌដូច្នេះ វាពុំមែនជារឿងមួយដែលគួរឱ្យងឿងឆ្ងល់ទេ នៅពេលដែលសាក្សីអាចបញ្ជាក់អំពីឈ្មោះរបស់លោក KIERNAN តាមរយៈរូបថតដែលគាត់បានឃើញនោះ។

[18] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៤ (ភាសាបារាំង)។

២៦. ការអនុវត្តដូច្នេះ គឺជាការរំលោភលើអត្ថប្រយោជន៍នៃការកោះហៅសាក្សី ហើយបានរំលង បុព្វសិទ្ធិនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ សេចក្ដីសម្រេចលេខ E141 ពុំបានអនុញ្ញាតដល់ អង្គភាពគាំពារសាក្សី និងអ្នកជំនាញឱ្យធ្វើការប្រគល់ឯកសារដល់សាក្សីឡើយ។ ផ្ទុយទៅវិញ សេចក្ដីសម្រេចនោះបានកម្រិតការធ្វើសកម្មភាពរបស់អង្គភាពនេះ ដោយហេតុសេចក្ដីសម្រេចនេះ បានបង្គាប់ឱ្យមានការដកយកឯកសារទៅវិញ ហើយកម្ទេចចោល ក្រោយពេលដែលសាក្សីបាន ពិនិត្យរួចហើយ[19]។

## ២. ការដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវរូបថតរបស់លោក KIERNAN

២៧. នៅក្នុងពេលសវនាការ ខណៈដែលរូបថតនេះត្រូវបានបង្ហាញដោយសាក្សី [20] លោកប្រធានអង្គជំនុំ ជម្រះក៏បានបង្គាប់ឱ្យដាក់បញ្ចូលរូបថតនេះទៅក្នុងសំណុំរឿង[21]។ ការដាក់បញ្ចូលនេះត្រូវបានធ្វើ មុនពេលដែលគេបានដឹងថា ឯកសារមួយនេះត្រូវបានប្រគល់ដល់សាក្សីដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។

២៨. ក៏ប៉ុន្តែ ផ្អែកតាមឆន្ទៈរបស់អង្គជំនុំជម្រះ ការបង្គាប់ឱ្យដាក់បញ្ចូលរូបថតនេះទៅក្នុងសំណុំរឿងគឺ ដើម្បីបង្ហាញអំពីសច្ចភាពដែលថាសាក្សីបានស្គាល់លោក KIERNAN ពិតប្រាកដមែន។

២៩. មេធាវីការពារក្ដីសូមធ្វើការជំទាស់ទៅនឹងការណ៍ដែលថា ការដាក់បញ្ចូលនេះនឹងអាចបញ្ជាក់ឱ្យ បានកាន់តែច្បាស់ថាសាក្សីពិតជាស្គាល់លោក KIERNAN នោះ។

៣០. ជាក់ស្ដែង ការដាក់បញ្ចូលត្រូវបានមើលឃើញថាជាគ្រោះថ្នាក់ ដែលកើតឡើងនៅក្នុងការអនុវត្ត ជាក់ស្ដែងរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ។

---

[19] *ការប្រគល់ចម្លើយមុនៗឱ្យសាក្សីមុនពេលសាក្សីធ្វើសក្ខីកម្មនៅសវនាការ* ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E141/1** ទំព័រ ១។

[20] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1** ទំព័រ ៧ និង ៨ (ភាសាបារាំង)។

[21] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1** ទំព័រ ៧៧ (ភាសាបារាំង)។

## III. ពាក់ព័ន្ធនឹងកំណត់ត្រាប្រគល់ជូនសាក្សីនៅមុនពេលផ្តល់សក្ខីកម្ម

៣១. ម្យ៉ាងវិញទៀត ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ពិតជាមានការអាក់អន់ចិត្ត នៅពេលដែលកំណត់ត្រារបស់ លោក KIERNAN[22] បកប្រែជាភាសាខ្មែរ ត្រូវបានប្រគល់ជូនសាក្សីនៅក្នុងល័ក្ខខ័ណ្ឌមួយដែលទាមទារឲ្យមានការស្រាយបំភ្លឺ។

៣២. ឯកសារទាំងអស់នេះមិនគួរត្រូវបានប្រគល់ជូនសាក្សី នូ ម៉ៅ នៅមុនពេលដែលគាត់ត្រូវចូលខ្លួនមកក្នុងសវនាការឡើយ។

៣៣. ដូចដែលក្រុមមេធាវីការពារក្តីបានរំលឹកពីខាងលើរួចមកហើយថា អង្គជំនុំជម្រះបានសម្រេចជាច្រើនលើកច្រើនសាលើបញ្ហានៃការបង្ហាញសក្ខីកម្មមុនៗ។ សក្ខីកម្មទាំងអស់នោះអាចត្រឹមតែជាសក្ខីកម្មដែលត្រូវបានធ្វើឡើងក្នុងដំណាក់កាលនៃការស៊ើបអង្កេត ដោយមានចុះហត្ថលេខា និងបញ្ជាក់ពីយថាភាពត្រឹមត្រូវ ហើយដែលខ្លឹមសាររបស់វាត្រូវបានអានឡើងវិញដោយសាក្សី ហើយអង្គជំនុំជម្រះបានបញ្ជូនសក្ខីកម្មទាំងនោះទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ ឯកសារដែលត្រូវបានប្រគល់ជូន លោក នូ ម៉ៅ ពុំមែនជាឯកសារប្រភេទនេះទេ។

៣៤. នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១០ នៅក្នុងលិខិតរបស់លោកផ្ញើជូនសហចៅក្រមស៊ើបអង្កេត លោក KIERNAN បានប្រកាសថា លោកជាអ្នកសរសេរកំណត់ត្រាទាំងអស់នោះ។ នៅក្នុងលិខិតនោះដែរ លោក KIERNAN បានបញ្ជាក់ថា លោក Michael VICKERY ទំនងជាមានខ្សែអាត់ថតសំឡេងនៃកិច្ចសម្ភាស ដែលនាំឲ្យមានកំណត់ត្រាទាំងអស់នោះ។[23]

៣៥. នៅក្នុងសារអេឡិកត្រូនិកចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១០ លោក Michael VICKERY បាន

---

[22] កំណត់ហេតុរបស់ Ben KIERNAN ឯកសារ **D313/1.2.405**។

[23] D296/4 ចម្លើយរបស់លោក Ben KIERNAN ជូនចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ២០១៤ ទំព័រ ២ (ភាសាបារាំង)

ប្រកាសជម្រាបសហាចៅក្រមស៊ើបអង្កេតថា៖ “*តាមពិតទៅ ខ្ញុំប្រហែលជាមានវត្តមានជាមួយលោក Kiernan នៅពេលនោះ ពីព្រោះយើងកំពុងធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា តែខ្ញុំមិនចាំពេលវេលានោះជាក់លាក់ទេ ហើយខ្ញុំក៏មិនមានឯកសារបញ្ជាក់ពីរឿងនេះដែរ។ វាអាចដែរ ដែលថាខ្ញុំបានថតខ្សែអាត់សំឡេង ប៉ុន្តែខ្ញុំបានបាត់វាទៅហើយ។*”[24]

៣៦. ដោយលោកចងចាំមិនបានច្បាស់ ហើយលោកក៏មិនបានរក្សាទុកនូវខ្សែអាត់សំឡេងនៃកិច្ចសម្ភាសផងនោះ លោក VICKERY បានត្រឹមតែសន្មតថា កិច្ចសម្ភាសនោះពិតជាមានមែន ដោយយើងមិនអាចពិនិត្យផ្ទៀងផ្ទាត់បានថា តើជំនួបនោះទំនងជាអាចកើតមានពិតប្រាកដមែននៅក្នុងល័ក្ខខ័ណ្ឌបែបណានោះទេ។

៣៧. បន្ទាប់មក លោក KIERNAN បានបដិសេធមិនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាអ្នកជំនាញ ដូចដែលអ្វីដែលអង្គជំនុំជម្រះបានកត់សម្គាល់នៅក្នុងអនុស្សរណៈរបស់ខ្លួន ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ដើម្បីប្រកាសបន្ទាប់ក្រោយមកថា អង្គជំនុំជម្រះផ្តល់“*តម្លៃតិចតួចស្តួចស្តើងប៉ុណ្ណោះ ឬមិនផ្តល់តម្លៃទាល់តែសោះ*”[25] ដល់ការងារដែលធ្វើដោយ លោក KIERNAN។

៣៨. ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន សូមរំលឹកផងដែរថា កំណត់ត្រាទាំងនោះពុំមានចុះហត្ថលេខា ឬស្នាមមេដៃទេ ហើយចំណារដែលបញ្ជាក់ថា “*សំឡេងមនុស្សម្នាក់ទៀត*”[26] បានបង្ហាញថា ប្រតិចារឹកត្រូវបានធ្វើឡើងក្រោយកិច្ចសម្ភាស។ ប្រសិនបើលោក KIERNAN មិនដឹងថា “សំឡេងមនុស្សម្នាក់ទៀត” នោះ ជាសំឡេងរបស់អ្នកណានោះ គឺមានន័យថា នៅពេលដែលលោកសរសេរកំណត់ត្រារបស់ខ្លួន លោក KIERNAN លែងដឹងថានរណាជាអ្នកនិយាយហើយនៅពេលនោះ។ ចំណារមួយនេះបង្ហាញឲ្យឃើញថា កំណត់ត្រាទាំងអស់នោះត្រូវបានសរសេរឡើងក្រោយកិច្ចសម្ភាស ប្រហែលជាតាមរយៈការស្តាប់ខ្សែអាត់សំឡេង។ លើសពីនេះទៅទៀត សាក្សី

---

[24] *សារអេឡិកត្រូនិករបស់ លោក Michael VICKERY* ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១០ ឯកសារ **D269/8/1.1**។

[25] សក្ខីកម្មរបស់ Benedict KIERNAN ដែលភាគីបានស្នើសុំ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អនុស្សរណៈចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ **E166/1/4** កថាខណ្ឌបន្ទាប់ចុងក្រោយ។

[2626] ឯកសារ **D313/1.2.405**, ERN ឯកសារជាភាសាអង់គ្លេស៖ 00419466។

បានបញ្ជាក់ថា ខ្លួនមិនបានអានឡើងវិញនូវកំណត់ត្រាទាំងអស់ដែលលោក KIERNAN អាចនឹងកត់ត្រាជាភាសាអង់គ្លេសក្នុងអំឡុងពេលនៃកិច្ចសម្ភាសឡើយ[27]។ ម្យ៉ាងវិញទៀត យើងគួរកត់សម្គាល់ថា កំណត់ត្រាទាំងអស់នោះមិនមែនជាប្រតិចារឹកទាំងស្រុងនៃកិច្ចសម្ភាសទេ ពីព្រោះថាគេពុំឃើញសំណួរដែលត្រូវបានសួរទៅកាន់សាក្សី មាននៅក្នុងកំណត់ហេតុនោះទេ។ ផ្អែកតាមហេតុផលនេះ យើងមិនអាចដឹងបានថា តើឈ្មោះទាំងអស់ដែលមាននៅក្នុងកំណត់ត្រានោះ ត្រូវបានលើកឡើងភ្លាមៗដោយអ្នកអ្នកផ្តល់បទសម្ភាស ឬក៏ជាការស្នើរបស់អ្នកធ្វើសម្ភាស។

៣៩. ជាទីបញ្ចប់ បញ្ហាលើការបកប្រែកិច្ចសម្ភាសនេះនៅតែជាប្រធានដែលត្រូវពិភាក្សា៖ លោក KIERNAN បានអះអាងថា លោកបានធ្វើកិច្ចសម្ភាសនោះដោយខ្លួនឯង ចំណែកឯសាក្សីវិញបានប្រកាសថា ការបកប្រែកិច្ចសម្ភាសនោះ ត្រូវបានធ្វើដោយមនុស្សម្នាក់ផ្សេងទៀត[28]។

៤០. សេចក្តីសង្កេតទាំងអស់នេះគឺជាហេតុផលដែលតម្រូវឲ្យមានការសម្រេចថា វិធានទាំងអស់ដែលកំណត់ដោយអង្គជំនុំជម្រះពាក់ព័ន្ធនឹងការប្រគល់ជូនសាក្សីដែលត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម

---

[27] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ២៨ (ភាសាខ្មែរ)៖ *"បាទ ហ្នឹងហើយគាត់អានឲ្យខ្ញុំស្តាប់ គាត់អ្នកបកប្រែ"*។

[28] ជាក់ស្តែង នៅក្នុងលិខិតរបស់លោកដែលបានធ្វើជូនសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១០ នៅត្រង់កថាខណ្ឌ ៦ លោក Ben KIERNAN បាននិយាយលម្អិតអំពីកិច្ចសម្ភាសជាមួយលោក នូ ម៉ៅ។ នៅត្រង់កថាខណ្ឌ ៧ គាត់បានរៀបរាប់អំពីកិច្ចសម្ភាសផ្សេងទៀត ដែលមាននៅក្នុងឯកសារ D313/1.2.405 ដោយបញ្ជាក់ថាបានធ្វើកិច្ចសម្ភាសទាំងនោះជាភាសាខ្មែរ៖ *"ពីទំព័រ ១០ ដល់ទំព័រ ២៨ នៃឯកសារដដែល ជាការកត់ត្រាដោយដៃរបស់ខ្ញុំនូវកិច្ចសម្ភាសផ្សេងៗដែលខ្ញុំធ្វើឡើងជាភាសាខ្មែរ ហើយខ្ញុំសរសេរជាភាសាអង់គ្លេស តាមខ្សែអាត់សម្លេងដែលខ្ញុំបានថត"*។ ភាពស្រដៀងគ្នានៃប្រធានបទកិច្ចសម្ភាស (តា ម៉ុក និងគោលនយោបាយរបស់ភូមិភាគនិរតី) កាលបរិច្ឆេទសម្ភាសជិតៗគ្នា (ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៨០ ត្រង់ទំព័រដែលមាន ERN 00419467 និងថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ត្រង់ទំព័រដែលមាន ERN 00419479) ការបង់លេខទំព័រឯកសារច្បាប់ដើម (ពីទំព័រ ៥០០ ដល់ទំព័រ ៥១៥) អាចឲ្យជឿជាក់បានថា កំណត់ត្រាដែលត្រូវបានសរសេរក្រោយកិច្ចសម្ភាសជាមួយ នូ ម៉ៅ និងកំណត់ត្រាដែលត្រូវបានសរសេរក្នុងកិច្ចសម្ភាសផ្សេងៗទៀតនៃឯកសារនោះ ត្រូវបានធ្វើឡើងក្នុងពេលតែមួយ។ លោក Ben KIERNAN និងសាក្សី និយាយផ្ទុយគ្នា ដោយលោក Ben KIERNAN អះអាងថា គាត់បានធ្វើកិច្ចសម្ភាសផ្សេងៗជាភាសាខ្មែរ មុននឹងសម្ភាសជាមួយសាក្សី រីឯសាក្សីវិញអះអាងថា នៅឆ្នាំ ១៩៨១ លោក Ben KIERNAN មិនទាន់ចេះភាសាខ្មែរទេ (សូមមើលកំណត់ត្រាបន្ទាប់)។

នូវសក្ខីកម្មមុនៗ មិនអនុញ្ញាតឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញប្រគល់ជូននូវឯកសារនេះដល់លោក នូ ម៉ៅ បានទេ។

**<u>ភាពប្រទាក់ប្រទង់នៃសក្ខីកម្មរបស់ លោក នូ ម៉ៅ</u>**

៤១. សវនាការកាលពីថ្ងៃទី ១៩ និង ទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ បានអនុញ្ញាតឱ្យភាគីទាំងអស់ និងអង្គជំនុំជម្រះ ធ្វើការកត់សម្គាល់ពីភាពមិនស៊ីសង្វាក់គ្នាសំខាន់ៗជាច្រើននៅក្នុងសក្ខីកម្មដោយធ្វើសម្បថរបស់សាក្សី[29]។ អាយុ ស្ថានភាពសុខភាព និងការភាន់ច្រឡំរបស់សាក្សី បានធ្វើឱ្យសក្ខីកម្មរបស់គាត់ពិបាកយល់។ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមរំលឹកថា ទាំងសហព្រះរាជអាជ្ញា ទាំងក្រុមមេធាវីការពារក្តី មានការលំបាកជាខ្លាំងចំពោះសាក្សី នូ ម៉ៅ ព្រោះថាសាក្សីរូបនេះមិនយល់ពីសំណួរនានា[30] ដែលបាទចោទសួរទៅលោក ទោះបីជាប្រភេទសំណួរងាយៗក៏ដោយ។

៤២. សាក្សីក៏បាននិយាយដដែលៗជាច្រើនលើកច្រើនសាផងដែរថា ទោះបីជាខ្លួនបានអានកំណត់ហេតុដែលគេបានប្រគល់ជូនលោកមុនក៏ដោយ ក៏លោកមិនអាចចាំបាននូវព័ត៌មានទាំងអស់បានទេ៖ *"ខ្ញុំបានអានដែរ អានសាចុះសាឡើងនៅក្នុងឯកសារហ្នឹង។ តែគ្រាន់ថាអានទៅដូចថាវាការចងចាំវានៅមានការភ្លេច ភ្លេចនោះវាភ្លេចច្រើនមែន។ វាអត់ចាំ។"*[31]

៤៣. ក្រោយមក លោក នូ ម៉ៅ បានប្រកាសថា៖

---

[29] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1** ទំព័រ ១១ ទំព័រ ២៦ ទំព័រ ៥០ (ភាសាបារាំង), ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ១៥ (ភាសាបារាំង), ចំពោះការនិយាយផ្ទុយគ្នា សូមមើលប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៥៣ និងទំព័របន្តបន្ទាប់ទៀត (ភាសាបារាំង)។

[30] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1** ទំព័រ ១០ បន្ទាត់ ៩ ដល់ ១៦ (ភាសាបារាំង), ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៨ បន្ទាត់ ១១ ដល់ ១៨ (ភាសាបារាំង)។

[31] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៩ (ភាសាបារាំង)។

*"ឲ្យមុន កាលខ្ញុំនៅផ្ទះនោះ។ គាត់យកឯកសារហ្នឹងយកឲ្យខ្ញុំ។ ខ្ញុំចេះតែអានមើលតាមឯកសារនោះទៅ ខ្ញុំថាដូចជាច្រើនពេក អានទៅវាទាក់ទងនៅក្នុងឯកសារហ្នឹងវាវែងពេក។ អ៊ីចឹងខ្ញុំដល់ច្រើនពេក ខ្ញុំរកចាប់ត្រង់ណាមិនជាប់ ណាវាភ្លេចភ្លាំងច្រើនពេកទៅ។"*[32]

៤៤. សក្ខីកម្មមិនច្បាស់លាស់ទាំងអស់នោះ បាននាំឲ្យយើងសន្និដ្ឋានបានថា សាក្សីបានគិតថាអង្គជំនុំជម្រះចង់បានឲ្យលោកចងចាំនូវអ្វីៗទាំងឡាយដែលលោកបានអាន ហើយដែលលោកត្រូវនិយាយពាក្យទាំងអស់នោះដដែលៗ។ ប៉ុន្តែ ដូចដែលបានបញ្ជាក់ពីខាងលើរួចមកហើយថា កំណត់ហេតុរបស់លោក KIERNAN មិនអាចត្រូវបានចាត់ទុកជាសក្ខីកម្មមុនៗរបស់សាក្សីឡើយ។ ទោះបីជាអង្គជំនុំជម្រះបានសុំឲ្យសហព្រះរាជអាជ្ញាសួរសំណួរបឋមទៅកាន់សាក្សី មុននឹងអនុញ្ញាតឲ្យធ្វើការ"រំលឹក"ការចងចាំរបស់សាក្សី តាមរយៈការអានអត្ថបទដកស្រង់ពីកំណត់ហេតុរបស់លោក KIERNAN ក៏ដោយ[33] ក៏ការអនុវត្តបែបនេះពុំមានន័យអ្វីឡើយ ពីព្រោះថាសាក្សីបានអានឡើងវិញនូវឯកសារនោះជាច្រើនលើកច្រើនសារួចមកហើយ មុននឹងគាត់ចូលខ្លួនមកផ្តល់សក្ខីកម្ម។

៤៥. ចំណុចនេះពិតជាសំខាន់ខ្លាំងណាស់ ព្រោះថាសាក្សីរូបនេះត្រូវបានកោះហៅជាពិសេសឲ្យចូលខ្លួនមកតុលាការដើម្បីដាក់បន្ទុកលើរូបលោក ខៀវ សំផន។ ដោយសារ ឈ្មោះគាត់ហ្នឹង មាននៅក្នុងកំណត់ហេតុរបស់លោក KIERNAN។ ក៏ប៉ុន្តែ អង្គជំនុះជម្រះនឹងសង្កេតឃើញថាការលើកឡើងរបស់សាក្សី ដែលអះអាងថាជាគំនិតរបស់លោក ខៀវ សំផន អំពីការជម្លៀសប្រជាជននេះ គឺមិនមែនចេញមកដោយឯកឯងនោះទេ ពោលគឺបន្ទាប់ពីទទួលបានសំនួរដឹកមុខរបស់សហព្រះរាជូអាជ្ញាអន្តរជាតិលើចំនុចនេះ។

---

[32] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៤០ (ភាសាបារាំង)។

[33] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1** ទំព័រ ៩ ទំព័រ ១៣ ទំព័រ ១៤ ទំព័រ ២០ ទំព័រ ៥៥ (ភាសាបារាំង)។ នៅក្នុងប្រតិចារឹកដដែលនោះ លោកប្រធានអង្គជំនុំជម្រះខ្លួនលោកផ្ទាល់ ក៏បានទទួលស្គាល់ថា ការសួរសំណួរបឋមមានភាពចាំបាច់៖ *"លោករៀបចំនូវសំណួរឲ្យបានសមស្របចៀសវាងនូវសំណួរនាំមុខ ឬក៏សំណួរបែបម៉្យាងមានបញ្ហាពាក់ព័ន្ធទៅនឹងឯកសារនេះ ដែលលោកដកស្រង់ចាត់ទុកឯកសារនេះគឺវាត្រឹមត្រូវជាមូលដ្ឋាន ដូចឯកសារដែលធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ឯកសារនេះវាខុសពីខ្លឹមសារនៃកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីរូបនេះនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។"* ទំព័រ ១៧ (ភាសាខ្មែរ)។

៤៦. ជាដំបូង បន្ទាប់ពីមានសំនួរបើកពីរ អំពីជំហររបស់អ្នកដឹកនាំលើការជម្លៀសប្រជាជន សាក្សីបាន ឆ្លើយថា គាត់មិនបានដឹងអ្វីសោះពីបញ្ហានេះ ហើយថាហេតុអ្វីបានគាត់មិនអាចដឹងពីរឿងទាំងអស់ នោះបាន។ នៅថ្ងៃទៅ១៩ ខែមិថុនា ២០១៣ នៅម៉ោង ១១ និង ០៨នាទី សាក្សីថាគាត់មិនបានដឹង ពីគោលជំហររបស់ថ្នាក់ដឹកនាំជាន់ខ្ពស់លើបញ្ហាជម្លៀសប្រជាជននេះទេ :

*"**ស៖** ខ្ញុំសួរអំពីឆ្នាំ១៩៧៥វិញម្តង។ លោកបានលើកឡើងអំពីការយល់ឃើញរបស់ តាម៉ុក ថាផែនការជម្លៀសប្រជាជនទីក្រុងភ្នំពេញនោះយ៉ាងម៉េចដែរនៅពេលនោះ? លោកបាន លើកឡើងការយល់ឃើញរបស់ ជូ ជេត អំពីផែនការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញផងដែរ។ តើលោកធ្លាប់បានដឹងដែរ ឬទេ ផែនការជម្លៀសរបស់មេដឹកនាំ ក្រៅពី ជូ ជេត និងគំនិតរបស់ តាម៉ុក នោះតើលោកដឹងផែនការ របស់គេផ្សេងទៀតដែរឬទេ អំពីការជម្លៀសមេដឹកនាំផ្សេង ទៀត?*

***ឆ៖*** *ត្រង់ហ្នឹងខ្ញុំមិនបានដឹងទេ។ ហ្នឹងហើយ គេហៅថា ខ្ញុំវាត្រឹមថ្នាក់ឃុំបាទ មិនអាច បានដឹងដល់ពីរឿងថា តើ តាម៉ុក ហើយនិង តាស៊ី ហ្នឹងគាត់បាននិយាយលើកឡើងថាមួយមិនឲ្យ ជម្លៀស មួយឲ្យជម្លៀសនេះ។ ខ្ញុំគ្រាន់តែបានឮដែលគេទៅប្រជុំបាទ អ្នកដែលចូលប្រជុំទាល់តែ បក្ខជន ហ្នឹងបានគេឲ្យទៅចូលរួម។ រីឯខ្ញុំគ្រាន់តែជាសមាជិកឃុំមួយតូចទេ គ្រាន់តែបានគេ ប្រើទេ។ លើកឡើងនេះមិនមែនថាខ្ញុំនេះមិនចង់រាយការណ៍ជូនដល់លោកប្រធានឲ្យជ្រាបថា តើ តាម៉ុក ហើយនិង តាស៊ី ហ្នឹងវាយ៉ាងម៉េច ដែលមួយឲ្យជម្លៀស មួយមិនឲ្យជម្លៀសហ្នឹង ខ្ញុំមិន បានដឹង។ ខាងផ្នែកនយោបាយធ្លាប់រៀនដែរគាត់ហៅទៅ។ ប៉ុន្តែគ្រាន់តែត្រង់មួយប្រជុំនៅក្នុង សន្និបាតខាងបក្សមួយៗហ្នឹង ខ្ញុំអត់បានចូលរួមទេ។ ហ្នឹងសូមអធ្យាស្រ័យ ដឹងតែប៉ុណ្ណឹង។"* [34]

៤៧. គឺនៅក្នុងខក្ខខណ្ឌបែបនេះហើយ នៅម៉ោង១១ និង១២ នាទី សហព្រះរាជអាជ្ញាបានលើកយកឃ្លា មួយនៅក្នុងកំណត់ហេតុរបស់លោក KIERNAN ក្នុងនោះមាននិយាយអំពីលោក ខៀវ សំផន :

*"**ស៖** ខ្ញុំយោងលើកឯកសារអង់គ្លេសគឺលេខ 00419458, ខ្មែរគឺ00909936, បារាំង 00893546។ ឯកសារនេះបានរៀបរាប់ដូចតទៅ "នៅក្នុងឆ្នាំ១៩៧៤ទេ -- នៅពេលនោះគឺថាគេ*

---

[34] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1**។ ទំព័រ ៣៦ នឹង៣៧(ភាសាបារាំង)។

*រៀបចំ ផែនការចាប់យកទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនទីក្រុងភ្នំពេញ។ អ្នកខ្លះគាំទ្រឱ្យជម្លៀស ហើយមនុស្សមួយចំនួនទៀតមិនគាំទ្រឱ្យមានការជម្លៀសប្រជាជននោះឡើយ។ ស៊ី មិនចង់ឱ្យមានការជម្លៀសប្រជាជននោះឡើយ។ ហើយ ហ៊ូ នឹម ក៏មិនចង់ឱ្យមានការជម្លៀសប្រជាជនផងដែរ"។ បន្ទាប់មកនៅក្នុងរង្វង់ក្រចក គេដាក់ថា "ហ៊ូ យន់?"។ ម៉ុក និងខៀវ សំផន គាំទ្រឱ្យមានការជម្លៀសប្រជាជននៅក្នុងឆ្នាំ១៩៧៤"។ លោក នួ មោក តើលោកនឹកឃើញទេ? នៅក្នុងពាក្យនេះ គេប្រើថា "ម៉ុក និង ខៀវ សំផន គាំទ្រឱ្យមានជម្លៀសប្រជាជននៅក្នុងឆ្នាំ១៩៧៤"។ តើលោកនឹកឃើញទេ?*

***លោក នួ ម៉ៅ៖***

***ឆ៖*** *ខ្ញុំបាទ អត់នឹកឃើញទេ ខ្ញុំបាទ។ វាបាត់បង់--"*[35]

៤៨. ដូច្នេះសហព្រះរាជអាជ្ញាអន្តរជាតិបានសង្កត់ធ្ងន់បន្ថែមទៀត។ នៅម៉ោង១១ នឹង២៣នាទី សហព្រះរាជអាជ្ញាក៏បានសួរសំនួរដដែលជាថ្មីម្តងទៀត សង្កត់បន្ថែមបន្ទាប់ពីទទួលបានចម្លើយច្របូកច្របល់ ហើយនៅម៉ោង១១ នឹង២៥នាទីក៏ទទួលបានចម្លើយមួយដែលផ្ទុយគ្នាទៅនឹងចម្លើយទាំងពីរដែលទទួលបានពីមុនមក :

***"ស៖*** *នៅក្នុងពេលនោះ គឺឆ្នាំ១៩៧៤ ដដែល។ តើលោកបានដឹងទេ ខៀវ សំផន នេះយល់យ៉ាងម៉េចដែរអំពីផែនការជម្លៀសនោះ?*

***ឆ៖*** *ខៀវ សំផន -- តែខ្ញុំអត់សួរគាត់ទេ -- ខៀវ សំផន, ហ៊ូ នឹមៗ, ហ៊ូ យន់ ភ្លេចបាត់ទៀតហើយ។ ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន -- ហ៊ូ នឹម --*

***ស៖*** *សូមអធ្យាស្រ័យ ខ្ញុំសូមបញ្ជាក់សំណួររបស់ខ្ញុំឡើងវិញលោកសាក្សី។ ខ្ញុំមិនបានសួរថា តើលោកស្គាល់ ឬក៏មិនស្គាល់លោក ខៀវ សំផន នោះទេ។ ខ្ញុំចង់សួរលោកថាតើលោកបានដឹងពីប្រភពណាផ្សេងមកដែរឬទេ ថាតើលោក ខៀវ សំផន គាំទ្រផែនការជម្លៀស ឬក៏គាត់ប្រឆាំងនឹងផែនការជម្លៀស?*

---

[35] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1**។ ទំព័រ ៣៨(ភាសាបារាំង)។

*ឆ៖ បើតាមជំហររបស់លោក ខៀវ សំផន គាត់ថាឲ្យជម្លៀស។ ជម្លៀសប្រជាជន។ ហ៊ូ យន់ គាត់មិនឲ្យជម្លៀសប្រជាជនទេ។ បើ ហ៊ូនឹម ក៏គាត់មិនឲ្យជម្លៀសប្រជាជនដែរហ៊ូ នឹម។"* [36]

៤៩. ក៏ប៉ុន្តែ ស្អែកឡើង សាក្សីនិយាយផ្ទុយម្តងទៀតនៅពេលឆ្លើយទៅនឹងសំនួររបស់សហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន សាក្សីបានឆ្លើយយ៉ាងច្បាស់ថា គាត់មិនអាចដឹងបានថាលោកខៀវសំផន យល់ស្របឬ ជំទាស់ការជម្លៀសប្រជាជននោះទេ :

*" **ស្វាយោយកញ្ញា អង់តា ហ្គីសាសេ៖***

*សៈ ដូច្នេះតាមចម្លើយរបស់លោក កាលពីម្សិលមិញយើងយល់ថា នៅក្នុងសន្និបាតនៅក្នុងវត្តតាំងពោធិ៍នេះ លោកបានដឹងអំពីជំហររបស់លោក ខៀវ សំផន និង ហ៊ូ នឹម។ តើលោកអាចពន្យល់ឲ្យបានច្បាស់ទេថា លោកដឹង ឬក៏មិនដឹងអំពីជំហររបស់លោក ខៀវ សំផន និង ហ៊ូ នឹម នេះពាក់ព័ន្ធទៅនឹងផែនការជម្លៀសចេញទីក្រុងភ្នំពេញ?*

*[១៤:១១:២២៥]*

***លោក នូ ម៉ៅ៖***

*ឆ៖ ខ្ញុំបាទខ្ញុំមិនបានដឹងទេ ជំហរ។ ដូចខ្ញុំបានលើកឡើង ខ្ញុំដែលលោក ហ៊ូ យន់ លោកប្រកាសរឿងជម្លៀសប្រជាជនពីទីក្រុង គាត់ថាមិនបាច់ជម្លៀសទេ តែដោយឡែកលោក ខៀវ សំផន និងលោក ហ៊ូ នឹម ខ្ញុំអត់ស្គាល់គាត់ ហើយក៏ចូលក្នុងការសន្និបាតហ្នឹង ក៏ខ្ញុំមិនៗស្គាល់ដែរ។ ហ្នឹងសូមមានតែប៉ុណ្ណឹង។"* [37]

៥០. ក្នុងល័ក្ខខ័ណ្ឌទាំងអស់នេះ ក្រុមមេធាវីការពារក្តីសូមធ្វើការគូសបញ្ជាក់ថា ការបង្ហាញជាមុនដល់លោក នូ ម៉ៅ នូវប្រតិចារឹកកិច្ចសម្ភាសដែលលោកបានអះអាងថាជាកិច្ចសម្ភាសរបស់លោកជាមួយលោក KIERNAN កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨១ នោះ ពិតជាបានបង្កឲ្យលោក

[36] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/209.1** ទំព័រ ៤១ (ភាសាបារាំង)។

[37] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៥៥ នឹង៥៦ (ភាសាបារាំង)។

មានការភាន់ច្រឡំកាន់តែធ្ងន់ធ្ងរ និងបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សក្ខីកម្មរបស់លោក។ មេធាវីការពារក្តីលោក ខៀវ សំផន ចាត់ទុកថា សាក្សីរូបនេះបានទទួលឥទ្ធិពលតាមរយៈការបង្ហាញឯកសារជាមុនបែបនេះ ដែលផ្ទុយពីសេចក្តីបង្គាប់របស់អង្គជំនុំជម្រះ។

## ផ្នែកតាងសំអាងហេតុទាំងអស់នេះ

៥១. ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន សូមស្នើឱ្យអង្គជំនុំជម្រះមេត្តា៖

- **ធ្វើការស៊ើបអង្កេត**លើល័ក្ខខ័ណ្ឌពិតប្រាកដនៃការប្រព្រឹត្តទៅនៃការកោះហៅសាក្សី នូ ម៉ៅ ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជាពិសេស លើអ្នកដែលបានសម្រេចឱ្យបង្ហាញ និងប្រគល់ជូនសាក្សី នូវរូបថតមួយសន្លឹកដែលមានសរសេរឈ្មោះលោក Ben KIERNAN។
- **បង្គាប់ឱ្យ**ប្រគល់ជូនដល់គ្រប់ភាគីទាំងអស់ នូវកំណត់ហេតុស្តីពីការកោះហៅសាក្សី នូ ម៉ៅ ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។
- **ធ្វើការស៊ើបអង្កេត**លើល័ក្ខខ័ណ្ឌពិតប្រាកដ និងលើការបញ្ជារបស់អាជ្ញាធរណាមួយដែលនាំឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ប្រគល់ឯកសារ D313/1.2.405 បកប្រែជាភាសាខ្មែរ ជូនលោក នូ ម៉ៅ មុនពេលដែលសាក្សីរូបនេះចូលខ្លួនមកផ្តល់សក្ខីកម្ម។
- **បង្គាប់ឱ្យ**ប្រគល់ជូនដល់គ្រប់ភាគីទាំងអស់ នូវឯកសារថតចម្លងចំនួនមួយច្បាប់នៃឯកសារដែលត្រូវបានប្រគល់ជូនសាក្សីនៅមុនពេលគាត់ចូលខ្លួនមកផ្តល់សក្ខីកម្ម។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងភ្នំពេញ | |